## ៥ សញ្ញាសម្គាល់សម្រាប់ជ័យលាភី ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

### ក- រូបសញ្ញា




**ខ- សញ្ញាសម្គាល់សម្រាប់ជ័យលាភីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**
មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរូបរាងជាក្បាច់ត្របកឈូកសំប៉ែត អមពទ្ធជុំវិញដោយសន្លឹកក្បាច់ភ្ញីទេសពណ៌មាស ទំហំកម្ពស់ ២៥ម.ម. និងទទឹង១៧ម.ម.

- ផ្នែកខាងលើកំពូលមានពន្លឺរស្មីដែលរះចែងចាំងចេញពីមកុដរាជពណ៌មាស ចំនួន២៥ ហើយនៅចំកណ្តាលនៃមកុដរាជមានរូបកងចក្រពណ៌មាស
- លម្អដោយក្បាច់ផ្កាច័ន្ទពណ៌មាសនៅខាងក្នុង។
ផ្នែកកណ្តាលមានរូបព្រះគណេសពណ៌មាស ដែលនៅអមសងខាងរូបព្រះគណេសមានលម្អដោយ ក្បាច់ផ្កាភ្ញីពណ៌មាស។ រីឯនៅខាងក្រោមព្រះគណេស រំលេចទៅដោយក្រណាត់បូមានពណ៌ក្រហម ខៀវ ហើយក្នុងផ្ទៃបូមានសរសេរពាក្យថា **«បរិញ្ញាបត្រជាន់ខ្ពស់-MASTER'S DEGREE»** ពណ៌មាស។

## ១.២- អត្ថន័យ

- **សន្ទឹកក្បាច់ភ្ញីទេស** តំណាងឱ្យការរីកចម្រើនលូតលាស់រុងរឿង សម្បូរសប្បាយ
- **ពន្លឺឆព្វណ្ណរង្សី** ស្ថិតនៅពីលើគេ តំណាងឱ្យគំនិត ប្រាជ្ញា ស្មារតី
- **មកុដរាជ** តំណាងឱ្យអំណាចរបស់ព្រះមហាក្សត្រ ដែលផ្តល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រនិងសិទ្ធិអំណាចដល់ស្ថាប័នជាតិ ក្នុងការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **កងចក្រ** តំណាងឱ្យប្រសិទ្ធភាព អំណាច និងសមត្ថកិច្ចក្នុងការអនុវត្តភារកិច្ចថែរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមទូទាំង២៥រាជធានី ខេត្ត
- **ព្រះគណេស** ជាអាទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គ និងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះព្រះគណេសតំណាងឱ្យភាពជាអ្នកប្រាជ្ញជាបណ្ឌិតជាអ្នកចេះដឹងអ្នកជួយដល់សត្វទាំងឡាយគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ព្រមទាំងបង្កើតឱ្យមានភាពសម្បូររុងរឿង វឌ្ឍនភាព និងវិបុលភាព
- **សន្ទឹកក្បាច់នៅអមព្រះគណេស** តំណាងឱ្យគំនិត ការច្នៃប្រឌិត និងនវានុវត្តន៍
- **បូពណ៌ខៀវ** និង **ក្រហម** រំលេចវគ្គសិក្សាថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់-MASTER'S**
- **DEGREE** ពណ៌មាសនៅចំកណ្តាល តំណាងឱ្យសន្តិសុខ សុវត្ថិភាពសង្គម សុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព ព្រមទាំងបង្ហាញពីភាពមោះមុត អង់អាចក្លាហាន ការប្តេជ្ញាចិត្ត ហ៊ានធ្វើពលិកម្ម និងតស៊ូប្រយុទ្ធ របស់កងកម្លាំងនគរបាលជាតិក្នុងការបម្រើជាតិនិងប្រជាពលរដ្ឋ
- **ពណ៌មាស** តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្តម សេចក្តីថ្លៃថ្នូរ គុណតម្លៃកងកម្លាំង និងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា
- អក្សរ **បរិញ្ញាបត្រជាន់ខ្ពស់-MASTER'S DEGREE** ជាឈ្មោះនៃកម្រិតសញ្ញាបត្រកម្រិតខ្ពស់ ដែលបណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើការបណ្តុះបណ្តាលដល់និស្សិតដែលជាមន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ។